Multicultural HIV/AIDS and Hepatitis C Service

NSW GOVERNMENT | Health

**NSW Health Factsheet - Khmer**

# កិច្ចបំរើផ្តល់ដោយក្រុមកិច្ចបំរើផ្នែកបង្ការ និងគ្រប់គ្រងរោគរបេង / មន្ទីរពិនិត្យសួត

## Services provided by Tuberculosis Prevention and Control Service / Chest Clinics

រដ្ឋញូវសៅវែល មានបណ្តាញនៃកិច្ចបំរើផ្នែកបង្ការ និងគ្រប់គ្រងរោគរបេង (TB) / មន្ទីរពិនិត្យសួតតាំងនៅពាសពេញក្នុងរដ្ឋ។ បណ្តាញនេះមានគោលបំណងផ្តល់នូវកិច្ចបំរើយ៉ាងទូលំទូលាយសមរម្យទៅតាមវប្បធម៌ ហើយដែលអាចទទួលបានដោយមនុស្សគ្រប់រូប។ គោលដៅរបស់យើងគឺដើម្បីព្យាបាលឲ្យជានូវរោគ TB កាត់បន្ថយរោគ TB និងការពារការឆ្លងរាលដាលនៃរោគ TB នៅក្នុងសហគមន៍។

តទៅនេះ គឺជាកិច្ចបំរើខ្លះៗផ្តល់ជូនដោយឥតគិតថ្លៃ ហើយរក្សាទុកជាសម្ងាត់ផ្តល់ដោយបណ្តាញបង្ការរោគ TB។

### ការវាយតម្លៃ និងធ្វើរោគវិនិច្ឆ័យរោគ TB

- ការពិនិត្យតាមដានរៀបចំឡើងចំពោះករណីដែលសង្ស័យថាមានរោគ TB
- ការធ្វើតេស្តលើស្បែកដើម្បីរកឲ្យឃើញការឆ្លងរោគ TB មិនទាន់ចេញមុខ (LTBI)
- សម្របសម្រួល និង / ឬរៀបចំការរកមើល និងការវាយតម្លៃមនុស្សដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមេរោគ TB
- កិច្ចបំរើផ្នែកកម្មរស្មីអិក្ស និងរោគសាស្ត្រសំរាប់ការឆែកពិនិត្យសុខភាពទាក់ទិននឹងរោគ TB
- ការពិគ្រោះយោបល់ផ្នែកពេទ្យសំរាប់អ្នកជម្ងឺ មានរួមទាំងការឲ្យចូលព្យាបាលនៅមន្ទីរពេទ្យ និងការមើលថែនៅតាមសហគមន៍
- ការពិគ្រោះយោបល់ផ្នែកពេទ្យចំពោះការប៉ះពាល់ត្រូវរោគ TB អ្នកវិជ្ជាជីវៈសហគមន៍ និងផ្នែកមើលថែសុខភាព
- ការរកមើល និងការត្រួតពិនិត្យរបស់ភ្នាក់ងារមើលថែសុខភាព ចំពោះស្ថានការណ៍រោគ TB។

### ការព្យាបាល និងការគ្រប់គ្រង

- ការសម្របសម្រួលនៃផែនការព្យាបាលសំរាប់បុគ្គលម្នាក់ៗ
- ការត្រួតពិនិត្យព្យាបាលរោគ TB នៅមន្ទីរព្យាបាល នៅផ្ទះ ឬនៅកន្លែងធ្វើការ
- ការព្យាបាលមេរោគ TB មិនទាន់ចេញមុខ
- ការរៀបចំអ្នកបកប្រែភាសាផ្នែកមើលថែសុខភាពសំរាប់បញ្ហារោគ TB។

### ការយល់ព្រមទទួលរ៉ាប់រងផ្នែកសុខភាព

- ការវាយតម្លៃ ការឆ្លុះថតមើល ការពិនិត្យជាបន្តទៀត ការត្រួតពិនិត្យ និងការអប់រំចំពោះអស់អ្នកដែលយល់ព្រមទទួលរ៉ាប់រងការព្យាបាលរោគ TB (TBU)។ TBU ត្រូវបានចេញដោយក្រសួងអន្តោប្រវេសន៍ និងការចូលសញ្ជាតិសំរាប់អ្នកចូលមកប្រទេសអូស្ត្រាលី ដែលគេត្រូវទទួលការវាយតម្លៃដោយកម្មរស្មីអិក្សដើម្បីថតមើលសួត ដែលចាំបាច់ត្រូវទទួលការពិនិត្យជាបន្តទៀត។

### ការឆ្លុះថតមើលសំរាប់ជនភៀសខ្លួន

- ការវាយតម្លៃ និងការឆ្លុះថតមើលសំរាប់កុមារជនភៀសខ្លួន ធ្វើព្រមជាមួយគ្នានឹងកិច្ចបំរើផ្នែកសុខភាពដទៃទៀត។

### ការចាក់ថ្នាំបង្ការរោគរបេង BCG

- ការចាក់ថ្នាំបង្ការរោគរបេង BCG ត្រូវបានណែនាំសំរាប់ក្រុមដែលបានជ្រើសតាំងដោយសារមានគ្រោះថ្នាក់រងប៉ះពាល់ត្រូវរោគ TB។

### កិច្ចបំរើផ្នែកអប់រំ និងការផ្តល់ឱវាទ

- ផ្តល់ឱវាទ និងការអប់រំចំពោះអ្នកជម្ងឺ សហគមន៍ និងអ្នកជំនាញការផ្នែកមើលថែសុខភាព អំពីការបង្ការជម្ងឺ ការព្យាបាល ការគ្រប់គ្រង និងការពិនិត្យរកមើលអំពីការប៉ះពាល់ត្រូវរោគ TB។

# ព័ត៌មានទូទៅ

## លទ្ធភាពទទួលយកកិច្ចបំរើ

ការណាត់ជួបនឹងតម្រូវឲ្យមានសំរាប់កិច្ចបំរើភាគច្រើន។ ដើម្បីទាក់ទងជាមួយមន្ទីរព្យាបាលដែលនៅជិតលោកអ្នកជាងគេ សូមមើលព័ត៌មានលំអិតនៅផ្នែកខាងក្រោមទំព័រនេះ។

## ការផ្លាស់ប្តូរការណាត់ជួប

ប្រសិនបើលោកអ្នកមិនអាចរក្សាការណាត់ជួបបានទេ សូមផ្តល់ព័ត៌មានដល់មន្ទីរព្យាបាល ដើម្បីឲ្យយើងផ្តល់ឱកាសនេះដល់អ្នកណាម្នាក់ដែលត្រូវការការណាត់ជួបជាបន្ទាន់។ ថ្ងៃខែ និងពេលវេលាសមរម្យមួយផ្សេងទៀតនឹងរៀបចំសំរាប់លោកអ្នក។

## ការយឺតយូរចំពោះការណាត់ជួប

ការប្រឹងប្រែងគ្រប់បែបយ៉ាងនឹងធ្វើឡើង ដើម្បីឲ្យបានជួបលោកអ្នកនៅពេលណាត់ជួប ក៏ប៉ុន្តែអាចមានឱកាសម្តងម្កាល នៅពេលដែលកិច្ចការនេះមិនអាចធ្វើបាន ដោយសារហេតុផលហួសពីសមត្ថភាពរបស់យើង ឧទាហរណ៍ ក្នុងករណីបន្ទាន់ដែលវេជ្ជបណ្ឌិតត្រូវបានហៅចេញពីមន្ទីរពិនិត្យរោគ។

## កិច្ចបំរើផ្តល់នៅតាមផ្ទះរបស់លោកអ្នក

អ្នកជម្ងឺខ្លះដែលទទួលការព្យាបាល TB មានសិទ្ធទទួលយកការពិនិត្យតាមផ្ទះ។ គិលានុប្បដ្ឋាកនឹងប្រាប់លោកអ្នកអំពីពេលវេលាដែលគេនឹងមកពិនិត្យលោកអ្នកនៅផ្ទះ។ ទោះជាយ៉ាងណាក្តី អាចមានពេលដែលកិច្ចការនេះមិនអាចធ្វើកើត ដោយសារមានភារៈកិច្ចដទៃទៀតដែលគេមិនអាចដឹងទុកមុន។

សូមប្រាប់គិលានុប្បដ្ឋាកឲ្យបានដឹងជាមុន ប្រសិនបើលោកអ្នកនឹងមិននៅផ្ទះ នៅចំពេលម៉ោងដែលបានណាត់ជួបនោះ។

## សន្តិសុខរបស់បុគ្គលិក

សន្តិសុខរបស់បុគ្គលិកយើង គឺជាការសំខាន់ចំពោះយើង ដោយហេតុនេះយើងស្នើសុំឲ្យលោកអ្នកសហប្រតិបត្តិការដើម្បីជួយធ្វើឲ្យប្រាកដថាបុគ្គលិកអាចទៅពិនិត្យនៅផ្ទះរបស់លោកអ្នកដោយសុវត្ថិភាព។ យើងស្នើសុំឲ្យលោកអ្នកចាប់បង្ខាំងទុកសត្វទាំងអស់ ពេលណាដែលគិលានុប្បដ្ឋាកត្រូវទៅពិនិត្យដល់ផ្ទះ។ នៅពេលពិនិត្យតាមផ្ទះជាលើកទីមួយ បុគ្គលិករបស់យើងនឹងឆែកមើលដើម្បីឲ្យបានដឹងថាតើមានបញ្ហាណាមួយទេដូចជាផ្លូវដើរមិនរាបស្មើល្អ ដែលអាចបណ្តាលឲ្យគេដួល។ យើងនឹងដកចេញនូវការពិនិត្យតាមផ្ទះ ប្រសិនបើយើងយល់ថាបុគ្គលិករបស់យើងមិនអាចមកពិនិត្យបានដោយសុវត្ថិភាព ហើយធ្វើការរៀបចំតាមមធ្យោបាយផ្សេងទៀតសំរាប់ការព្យាបាលជាបន្តទៀតរបស់លោកអ្នក។

**ចំពោះកិច្ចបំរើផ្នែករោគ TB ពុំចាំបាច់ត្រូវការប័ណ្ណមេឌីឃែរទេ**

**ការណែនាំបញ្ជូន ពុំមែនជាការចាំបាច់ដែលត្រូវតែមានគ្រប់ពេលនោះទេ**

**សូមមើលបញ្ជីរាយឈ្មោះកិច្ចបំរើបង្ការ និងគ្រប់គ្រងរោគ TB / មន្ទីរពិនិត្យសួតរង្គញូវសៅវែល។**